វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២៦ ខែ មេសា ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះគឺ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាប់ផ្តើមជ្រើសរើសអ្នកគ្រប់គ្រងសម្រាប់ធនាគារសហគ្រាសធុនតូច និងមធ្យមថ្នាក់ជាតិ
- ផលិតកម្មឧស្សាហកម្មរបស់តៃវ៉ាន់មានការធ្លាក់ចុះ រយៈពេល៤ខែជាប់ៗគ្នាគិតត្រឹមខែមីនា
- តម្លៃប្រេងឡើងខ្ពស់បន្ថែមទៀត បន្ទាប់ពីរដ្ឋបាលលោកត្រាំដាក់គោលដៅពាណិជ្ជកម្មជាមួយប្រទេសអ៊ីរ៉ង់

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះគឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីអោយការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាប់ផ្តើមជ្រើសរើសអ្នកគ្រប់គ្រងសម្រាប់ធនាគារសហគ្រាសធុនតូច និងមធ្យមថ្នាក់ជាតិ

យោងតាមកាសែតភ្នំពេញប៉ុស្តិ៍បានឱ្យដឹងថា ធនាគារសម្រាប់សហគ្រាសធុនតូច និងមធ្យមដែលជាធនាគាររបស់រដ្ឋត្រូវបានគេរំពឹងថានឹងចាប់ផ្តើមប្រតិបត្តិការនៅចុងឆ្នាំនេះ ខណៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានចាប់ផ្តើមជ្រើស-រើសបុគ្គលិកសម្រាប់តំណែងជាថ្នាក់ដឹកនាំផងដែរ។

ធនាគារសម្រាប់សហគ្រាសធុនតូច និងមធ្យមរបស់ប្រទេសកម្ពុជានេះ ត្រូវបានគេផ្តល់ប្រាក់ចំនួន១០០លានដុល្លារអាមេរិក ដើម្បីផ្តោតលើការអភិវឌ្ឍកសិ-ពាណិជ្ជកម្ម និងសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។ គោលដៅសំខាន់ៗរបស់ធនាគារគឺបង្កើនរោងចក្រកែច្នៃក្នុងស្រុក ជម្រុញការនាំចេញពង្រីកវិស័យពាណិជ្ជកម្ម និងបង្កើតការងារ។

### តារាងប្រចាំសប្តាហ៍៖ សន្និធិបំណុលសាធារណៈឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨

គិតត្រឹមចុងឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាមានបំណុលសាធារណៈសរុបចំនួន ៧ប៊ីលានដុល្លារអាមេរិក ដែលក្នុងនោះ 0,0៤% ឬទឹកប្រាក់ ២,៨លានដុល្លារអាមេរិកគឺជាបំណុលសាធារណៈក្នុងប្រទេស ក្រៅពីនេះគឺជាបំណុលសាធារណៈក្រៅប្រទេស ដែលនេះមានន័យថា ការធ្វើហិរញ្ញប្បទានរបស់កម្ពុជា ស្ទើរទាំងស្រុងមិនប្រើប្រាស់បំណុលដែលបានមកពីអ្នកឲ្យខ្ចីនៅក្នុងប្រទេសទេ។

បំណុលក្រៅប្រទេសត្រូវបានគេប្រើដើម្បីផ្តល់ហិរញ្ញប្បទានលើគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាព ដើម្បីជម្រុញផលិតភាពផលិតកម្ម និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរយៈពេលយូរ។

សន្ទិធិបំណុលសាធារណៈពីឆ្នាំ២០១៦ ដល់២០១៨




ប្រភពៈ [ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ]

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ផលិតកម្មឧស្សាហកម្មរបស់តៃវ៉ាន់ ធ្លាក់ចុះរយៈពេល៤ខែជាប់ៗគ្នាគិតត្រឹមខែមីនា

តាមរយៈគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចតៃវ៉ាន់ ទិន្នផលឧស្សាហកម្មនៅតៃវ៉ាន់ បានធ្លាក់ចុះ រយៈពេលបួនខែជាប់គ្នាដល់ត្រឹមខែមីនា ពោលគឺធ្លាក់ចុះ៩,៩% បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ការធ្លាក់ចុះនេះជាការធ្លាក់ចុះខ្លាំងចាប់តាំងពីខែមករាឆ្នាំ ២០១២ ដែលពេលនោះបានធ្លាក់ចុះ ១៥,៩%។

អនុសន្ទស្សន៍នៃវិស័យកម្មន្តសាល ដែលមានចំនួនជាង ៩០% នៃទិន្នផលឧស្សាហកម្មសរុប បានធ្លាក់ចុះ១០,៥% ធៀបទៅនឹងឆ្នាំមុន និងជាការធ្លាក់ចុះខ្លាំងគួរអោយកត់សម្គាល់តាំងពីខែមករា ឆ្នាំ២០១២ ដែលពេលនោះបានធ្លាក់ចុះចំនួន ១៦,៨%។

នៅក្នុងត្រីមាសទី១នៃឆ្នាំ២០១៩ ផលិតកម្មឧស្សាហកម្មបានធ្លាក់ចុះ៤,៩% ខណៈពេលដែលអនុសន្ទស្សន៍វិស័យកម្មន្តសាលបានថយចុះ ៤,៨%។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### តម្លៃប្រេងឡើងខ្ពស់បន្ថែមទៀត បន្ទាប់ពីរដ្ឋបាលលោកត្រាំដាក់គោលដៅពាណិជ្ជកម្មជាមួយប្រទេសអ៊ីរ៉ង់

តម្លៃប្រេងនៅពិភពលោកបានកើនឡើងខ្ពស់ក្នុងរយៈពេលជិត៦ខែ កាលពីថ្ងៃចន្ទ បន្ទាប់ពីរដ្ឋបាលលោកត្រាំប្រកាសថានឹងអាចលុបចោលការលើកលែងទណ្ឌកម្មដែលអនុញ្ញាតឲ្យប្រទេសចំនួន០៨ ទិញប្រេងឆៅពីអ៊ីរ៉ង់កាលពីកន្លងមក។ ប្រទេសទាំង០៨នោះ រួមមានចិន ឥណ្ឌា តួកគី ជប៉ុន កូរ៉េខាងត្បូង តៃវ៉ាន់ អ៊ីតាលី និងក្រិក។

កាលពីព្រឹកថ្ងៃចន្ទ ប្រេងឆៅប្រភេទBrent ដែលជាប្រេងដែលមានគុណភាពលំដាប់អន្តរជាតិបានកើនឡើង២,៥% ដែលមានតម្លៃប្រមាណ ៧៣,៧៧ដុល្លារក្នុង១បារ៉ែល រីឯប្រេងឆៅប្រភេទWest Texas Intermediate កើនឡើង ២,១% ដែលមានតម្លៃប្រមាណ ៦៥,៣៩ដុល្លារក្នុង១បារ៉ែល។

ការលុបចោលការលើកលែងការដាក់ទណ្ឌកម្មនេះមានគោលបំណងកាត់បន្ថយការនាំចេញប្រេងឆៅរបស់អ៊ីរ៉ង់អោយមកត្រឹមកម្រិតសូន្យ រហូតដល់អ៊ីរ៉ង់យល់ព្រមបោះបង់ចោលកម្មវិធីនុយក្លេអ៊ែរ និងមីស៊ីលគ្រាប់ផ្លោង និងបញ្ឈប់ទំនាក់ទំនងយោធាជាមួយប្រទេសស៊ីរី និងប្រទេសយេម៉ែន។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមានៈ ការចេញផ្សាយស្ថិតិខែមេសារបស់សរៀតណាមនៅថ្ងៃចន្ទ និងការសម្រេចលើអត្រាការប្រាក់របស់សហរដ្ឋអាមេរិកនៅថ្ងៃព្រហស្បតិ៍។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

ថ្ងៃចន្ទ ទី២៩ ខែមេសា

- អត្រានិកម្មភាពរបស់ថៃ សម្រាប់ខែមីនា
- ទំនុកចិត្តអ្នកប្រើប្រាស់នៅតំបន់អឺរ៉ុប សម្រាប់ខែមេសា
- អត្រាអតិផរណារបស់វៀតណាម សម្រាប់ខែមេសា
- តុល្យភាពពាណិជ្ជកម្មរបស់វៀតណាម សម្រាប់ខែមេសា
- ផលិតកម្មឧស្សាហកម្មរបស់វៀតណាម សម្រាប់ខែមេសា
- ការលក់រាយរបស់វៀតណាម សម្រាប់ខែមេសា

ថ្ងៃអង្គារ ទី៣០ ខែមេសា

- ផលិតកម្មឧស្សាហកម្មរបស់កូរ៉េខាងត្បូង សម្រាប់មីនា
- ការលក់រាយរបស់កូរ៉េខាងត្បូង សម្រាប់ខែមីនា
- សន្ទស្សន៍តម្លៃនៃអ្នកផលិតរបស់ហ្វីលីពីន សម្រាប់ខែមីនា
- ផលិតកម្មឧស្សាហកម្មរបស់ថៃ សម្រាប់ខែមីនា
- ការវិនិយោគផ្ទាល់ពីបរទេសរបស់ឥណ្ឌូនេស៊ី សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩
- គណនីចរន្តរបស់ថៃ សម្រាប់ខែមីនា
- ការលក់រាយរបស់ថៃ សម្រាប់ខែមីនា
- កិច្ចចរចារពាណិជ្ជកម្មរវាងចិន និងអាមេរិក

ថ្ងៃពុធ ទី០១ ខែឧសភា

- អត្រាអតិផរណារបស់ថៃ សម្រាប់ខែមេសា
- ការលក់ទោចក្រយានយន្តរបស់ឥណ្ឌូនេស៊ី សម្រាប់ខែមីនា
- តុល្យភាពពាណិជ្ជកម្មរបស់កូរ៉េខាងត្បូង សម្រាប់ខែមេសា

ថ្ងៃព្រហស្បតិ៍ ទី០២ ខែឧសភា

- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ធនាគារសហព័ន្ធអាមេរិក
- អត្រាអតិផរណារបស់ឥណ្ឌូនេស៊ី សម្រាប់ខែមេសា
- ភ្ញៀវទេសចររបស់ឥណ្ឌូនេស៊ី សម្រាប់ខែមីនា
- អត្រាអតិផរណារបស់កូរ៉េខាងត្បូង សម្រាប់ខែមេសា

ថ្ងៃសុក្រ ទី០៣ ខែឧសភា

- អត្រាអតិផរណានៅតំបន់អឺរ៉ុប សម្រាប់ខែមេសា
- ទំនុកចិត្តអាជីវកម្មនៅថៃ សម្រាប់ខែមេសា
- តុល្យភាពពាណិជ្ជកម្មនៅម៉ាឡេស៊ី សម្រាប់ខែមីនា
- ការលក់រាយនៅហុងកុង សម្រាប់ខែមីនា